**WEATHERGARD**

# តារាងទិន្នន័យបច្ចេកទេសថ្នាំលាប

# NIPPON WEATHEGARD

| | |
|---|---|
| បរិយាយ | **Nippon WeatherGard** ជាប្រភេទថ្នាំលាបដែលលាយជាមួយនឹងទឹក សំរាប់លាបជញ្ជាំងខាងក្រៅ អាចរក្សាពណ៌បានយូរ ធន់ជាមួយជាតិទឹក និង កំដៅថ្ងៃ។ |
| ប្រភេទ | ថ្នាំដែលមានជាតិការខ្ពស់ Modified Acrylic Emulsion |
| សាច់ថ្នាំ | រលោង |
| ពណ៌ | មានពណ៌ច្រើនប្រភេទសំរាប់ជ្រើសរើសក្នុងសៀវភៅពណ៌ រឺ ពណ៌ពិសេសអាចលាយបាន |
| ប្រើប្រាស់ | សំរាប់ធ្វើអោយមានសោភ័ណភាព ជាប់ពណ៌បានយូរ និង មានសារធាតុការពារសំរាប់ផ្ទៃខាងក្រៅដូចជា<br>► ជញ្ជាំងបូក<br>► ស៊ីម៉ង់ត៍/បេតុង<br>► ជញ្ជាំងឥដ្ឋ |

**លក្ខណះពិសេស**

- ការពារពីអាកាសធាតុគ្រប់ប្រភេទ និង ជាប់ពណ៌បានយូរ
- ការពារពីកំដៅថ្ងៃខ្លាំង ធ្វើអោយមានការសន្សំសំចៃដល់ការប្រើប្រាស់ថាមពលអគ្គិសនី
- ធន់នឹងទឹក មិនមានស្នាមប្រឡាក់
- ការពារការដុសស្លែ និង មានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងប្រឆាំងនឹងសារធាតុផ្សិត
- ងាយស្រួលសម្អាត និង ដុសលាងជាមួយទឹក រឺ សាប៊ូបាន
- ធន់នឹងទឹក ជាតិអំបិល កំបោរ និង សារធាតុដែលធ្វើអោយឆាប់ស្លកពណ៌
- ធន់នឹងការករកិត
- ងាយស្រួលក្នុងការលាបដែលធ្វើអោយថ្នាំស្មើសាច់ល្អ
- គ្មានសារធាតុពុល គ្មានក្លិន (មានសារធាតុផ្សំដែលកាត់បន្ថយក្លិនតិចជាង ៥០ក្រាម/លីត្រ, ស្របតាមបទដ្ឋានស្តង់ដាររបស់ **VOC)**
- គ្មានសារធាតុពុល មិនផ្ទុកនូវសារធាតុសំណរ បារ៉ត

**និន្នន័យនៃការប្រើប្រាស់**

ការរៀបចំផ្ទៃ ផ្ទៃលាបត្រូវតែស្ងួត ស្អាត និង ធន់ស្មើល្អ មុនពេលលាប ហើយត្រូវជួសជុលជាមុនប្រសិនបើមានបញ្ហាដូចខាងក្រោម

ស្នាមប្រឡាក់/ប៉ែកម្សៅ - លាងសម្អាតដោយប្រើម៉ាស៊ីនបាញ់ទឹកសម្ពាធខ្ពស់

- សម្អាតជាមួយនឹងក្រណាត់សើម, សំរាប់ផ្ទៃដែលមានជាតិម្សៅ ត្រូវលាបថ្នាំទ្រនាប់ Nippon HITEX 5180 1ជាន់សិន បន្ទាប់ពីសម្អាតរួច។

ផ្ទៃជញ្ជាំងដែលធ្លាប់លាបថ្នាំ - ឈូសថ្នាំចាស់ដែលខូចគុណភាពចោលដោយប្រើម៉ាស៊ីនបាញ់ទឹក រឺក្រដាសខាត់ អាចជ្រើសរើសវិធីណាមួយដែលសមស្រប

សំណើម - សំណើមខ្លាំងពេកអាចធ្វើអោយមានផលប៉ះពាល់ដល់ថ្នាំលាប, ដូចនេះសូមធ្វើការសង្កេតលើកំរិតសំណើមជាមុនសិន មុននឹងធ្វើការលាប៖

| | | |
|---|---|---|
| ផ្ទៃជញ្ជាំងស៊ីម៉ង់ត៍ | - | ក្រោម 6% |
| ផ្ទៃឈើ | - | ក្រោម 10% |

សំរាប់ផ្ទៃលាបដែលមានជ្រាបទឹកត្រូវជួសជុលជាមុនសិន

ផ្ទៃជញ្ជាំងប៉ូក - ផ្ទៃប៉ូកដែលមិនមានគុណភាពល្អត្រូវឈូសចេញដោយប្រើដែកឈូស រឺម៉ាស៊ីនឆាបដើម្បីអោយផ្ទៃរាបស្មើ

ស្លែ ខាត់ចេញដោយប្រើម៉ាស៊ីនបាញ់ទឹកសម្ពាធខ្ពស់ រឺ ម៉ាស៊ីនឆាប រួចលាងជាមួយទឹកស្អាតហើយទុកអោយស្ងួត។

ប្រេង/ខ្លាញ់ ប្រើជាមួយសាប៊ូ រឺ សារធាតុរំលាយខ្លះបើចាំបាច់។ ដុសលាងអោយស្អាតដើម្បីកម្ចាត់ផ្ទៃដែលមានជាតិប្រេង។

ល្បាយលាយ លាយជាមួយទឹកស្អាត

ឧបករណ៍លាប ជក់, រ៉ូឡូ និង ម៉ាស៊ីនបាញ់ឥតប្រើខ្យល់

លាបដោយប្រើ <u>ម៉ាស៊ីនបាញ់ឥតប្រើខ្យល់</u>

សម្ពាធខ្យល់ 120kg-150kg/$cm^2$

ក្បាលបាញ់ដែលមានមុំ 60° 0.017”

លាយទឹកច្រើនបំផុត 10%

<u>លាបដោយប្រើ ជក់ រឺ រ៉ូឡូ</u>

លាយទឹកច្រើនបំផុត 10%

**វិធីណែនាំប្រព័ន្ធនៃការលាប** ម្សៅបៀក Nippon 2-3 ស្រទាប់

លាបថ្នាំទ្រនាប់ Hitex 5180 1ស្រទាប់

លាបថ្នាំសំរេច Nippon WeatherGard 2ស្រទាប់

កំរាស់ណែនាំ 40-50 មីក្រុង (កំរាស់ពេលថ្នាំស្ងួត) ក្នុងមួយស្រទាប់សំរាប់ស្តង់ដានៃការលាប។

សមត្ថភាពគ្រប់ដណ្តប់ ទ្រឹស្តី 10.0m²/លីត្រ (កំរាស់ពេលថ្នាំស្ងួត 40 មីក្រុង)

អនុវត្ត: 9.0m²/លីត្រ (ដោយគិតពីកត្តាបាត់បង់ 10% រួចហើយ)

កត្តាបាត់បង់ជាក់ស្តែងផ្អែកលើលក្ខខណ្ឌនៃការប្រើឧបករណ៍លាប, វិធីសាស្រ្តលាប និង បច្ចេកទេសលាប, លក្ខខណ្ឌផ្ទៃលាប ក៏ដូចជាទំរង់ និង ទំហំនៃទីតាំងដែលត្រូវបានលាប។

រយៈពេលលាបក្នុងមួយស្រទាប់ៗ តិចបំផុត 2 ម៉ោងក្នុងលក្ខខណ្ឌធម្មតានៅសីតុណ្ហភាព 25-30 អង្សា ក្នុងកំរាស់សម្ងួត (40-50មីក្រុង)

រយៈពេលសម្ងួត ស្ងួតអាចប៉ះបាន 30 នាទីនៅសីតុណ្ហភាព 25-30 អង្សា ក្នុងកំរាស់សម្ងួត (40-50មីក្រុង)

ការសម្អាតឧបករណ៍លាប ត្រូវសម្អាតឧបករណ៍លាបភ្លាមៗជាមួយទឹកស្អាតបន្ទាប់ពីលាបរួច

ការរក្សាទុក : ទុកក្នុងកន្លែងស្ងួត និង ត្រជាក់ ហើយរក្សាគម្របអោយនៅបិតជិតជានិច្ច នៅចន្លោះសីតុណ្ហភាព ពី 5-40 អង្សា

**<u>ពត៏មានទូទៅ</u>**

រយៈពេលផុតកំណត់ : រហូតដល់ 12 ខែនៅពេលដែលគំរបបិតជិត ហើយក្នុងសីតុណ្ហភាព 25 អង្សា

ចំណុះក្នុងមួយធុង : 1 លីត្រ 5 លីត្រ និង 15 លីត្រ

ការប្រុងប្រយ័ត្ន : ជៀសវាងការប៉ះផ្ទាល់ជាមួយអ្នកមានបញ្ហាសើរស្បែក និង ត្រូវប្រើឧបករណ៍ផ្សេងៗដើម្បីការពារ

ពត៏មានដែលបានផ្តល់ជូនខាងលើនេះត្រូវបានសាកល្បងជាក់ស្តែងរួចរាល់។ ខាងយើងខ្ញុំមិនធានា រឺ ទទួលខុសត្រូវចំពោះលក្ខខណ្ឌនៃការអនុវត្តដែលខុសគ្នាខ្លាំង។ យើងរក្សាសិទ្ធក្នុងការកែប្រែលក្ខខណ្ឌផ្សេងៗដោយមិនជម្រាបជូនទុកជាមុន។

(*) ផ្អែកលើពណ៌សជាគោល

ISO 14001 REGISTERED
DNV
UKAS ENVIRONMENTAL MANAGEMENT
013
DNV Certification B.V. - The Netherlands

OHSAS 18001
DNV
REGISTERED